# ប្រវត្តិនៃវត្តឧណ្ណាលោម




រៀបរៀងដោយ

**សម្តេចព្រះមហាសុមេធាធិបតី**

**ជួន-ណាត**

**ជោតញ្ញាណោ**



បោះពុម្ពចំនួន ៦០០០ ក្បាល

សម្រាប់ចែកផ្សាយក្នុងឱកាសពិធីបុណ្យឆ្លងវិហារវត្តឧណ្ណាលោម

ពីថ្ងៃទី ១ ដល់ទី ៤ មិថុនា គ.ស. ១៩៦៣

# ប្រវត្តិនៃវត្តឧណ្ណាលោម

សង្កាត់លេខ ៣

ក្រុងភ្នំពេញ

រៀបរៀងដោយ


## សម្តេចព្រះមហាសុមេធាធិបតី

## ជួន-ណាត

ជោតញ្ញាណោ



បោះពុម្ពចំនួន ២ ០០០ ច្បាប់

សម្រាប់ចែកផ្សាយក្នុងឱកាសពិធីបុណ្យឆ្លងវិហារវត្តឧណ្ណាលោម

ពីថ្ងៃទី ១ ដល់ទី ៤ មិថុនា គ.ស. ១៩៦៣

ព.ស. ២៥០៦

# អារម្ភកថា

ប្រវត្តិនៃវត្តខ្ណារលោមនេះ ខ្ញុំបានរៀបរៀងពីក្នុងកាល ព.ស. ២៥០៥ គ.ស. ១៩៦២, ពុទ្ធិកសមាគមកម្ពុជរដ្ឋ បានបោះពុម្ពផ្សាយក្នុងពន្លឺពុទ្ធចក្រ ទស្សនាវដ្ដី ប្រចាំត្រីមាសលេខ ៨ ខែតុលា-វិច្ឆិកា-ធ្នូ ព.ស. ២៥០៥ រួចម្ដងទៅហើយ ។

ដោយពុទ្ធបរិស័ទភាគច្រើន ចង់បានប្រវត្តិនេះបែកផ្សាយក្នុងឱកាសពិធីបុណ្យឆ្លងវិហារ-បញ្ចុះខណ្ឌសីមាវត្តខ្ណារលោម នៅថ្ងៃទី ១-២-៣-៤ មិថុនា ព.ស. ២៥០៦ គ.ស. ១៩៦៣ ដើម្បីឲ្យសមនឹងពិធីបុណ្យឆ្លងវិហារនេះ ក៏បានសុំឲ្យខ្ញុំរៀបរៀងសេចក្ដីដោយសង្ខេប ថែមលើសជាងមុននោះខ្លះឡើងទៀត, ឯអនុស្សរណាហេតុ (ផ្សេងពីប្រវត្តិ) ចំពោះយុវជន (អ្នកនៅអាស្រ័យក្នុងវត្ត) នោះសុំឲ្យទុកទៅដូចដើម កុំឲ្យលែងចោល, ខ្ញុំក៏យល់ស្របតាមផងដែរ ព្រោះយល់ឃើញថាជាទិដ្ឋានុគតិ ឲ្យវត្តឯទៀតណាដែលពុំទាន់បានរៀបរៀងប្រវត្តិនៅឡើយនោះ យកគម្រាប់តាម ឲ្យវត្តទាំងនោះមានប្រវត្តិតទៅ ។

ប៉ុន្តែសេចក្ដីដែលខ្ញុំបានរៀបរៀងថែមឡើងទៀតនោះ ពុំបានសព្វគ្រប់ទេ គ្រាន់តែជាគោលខ្លី ៗ នៃការស្ថាបនាវិហារថ្មីនេះប៉ុណ្ណោះ ។

ថ្ងៃទី ១៦ ឧសភា ២៥០៦/១៩៦៣

សម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ

# ប្រវត្តិនៃវត្តឧណ្ណាលោម
## ក្រុងភ្នំពេញ

រៀបរៀងដោយសម្តេចព្រះមហាសុមេធាធិបតី

ជួន-ណាត

ជោតញ្ញាណោ

ប្រវត្តិនៃវត្តឧណ្ណាលោម ហាក់ទាក់ទងគ្នានឹងព្រះរាជពង្សាវតារនៃប្រទេសកម្ពុជាខ្លះផង. បើសុខតែស្រង់យករឿងក្នុងពាក្យព្រេងកម្ពុជាដោយសង្ខេបខ្លះ មករៀបរៀងផង ទើបប្រវត្តិនៃវត្តឧណ្ណាលោមរកចប់ដល់ហេតុការណ៍ខ្លះឲ្យជាក់ច្បាស់ឡើងបាន រឿងលេងតែប្រព្រឹត្តិការណ៍ខ្លះពីក្នុងអតីតកាលយូរអង្វែងហើយ ដូចយ៉ាងកំណើតនៃ មហាចេតិយឧណ្ណាលោម ជាដើម ដែលពុំដឹងជាកើតមានពីក្នុងសម័យណា ព្រោះព្រះរាជពង្សាវតារពុំបានចែងប្រាប់ ។

ក្នុងព្រះរាជពង្សាវតារនៃប្រទេសកម្ពុជា មានសេចក្តីថ្លែងថា ព្រះចាងសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់គ្រប់គ្រងរាជសម្បត្តិគង់នៅក្នុងព្រះបរមរាជវាំង មហានគរ (នគរធំ) បាន ១៩ ឆ្នាំ លុះដល់ឆ្នាំគំរប់ ១៦ នៃរជ្ជកាលរបស់ព្រះអង្គ ទើបទ្រង់មានព្រះយោបល់យល់ថា ទ្រង់ក្រាំនៅក្នុងមហានគរនេះតទៅទៀតពុំកើត ក៏មានព្រះរាជបញ្ជាឲ្យ

កសាងព្រះរាជវាំងថ្មីទៅ ទួលបាសាណ ក្នុងខេត្តស្រីសឈរ គឺក្នុងស្រុកស្រីសន្ធរខេត្តកំពង់ចាមសព្វថ្ងៃនេះ ។

នៅថ្ងៃ ១៣ រោចខែមិគសិរឆ្នាំជូតចត្វាស័ក ពុទ្ធសករាជ ១៩៧៦ ចុល្លសករាជ ៧៩៤ គ្រិស្តសករាជ ១៤៣៤ ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់ស្តេចយាងចេញចាកមហានគរ មួយអន្លើដោយរាជសេវកាមាត្យនាម៉ឺនសព្វមុខមន្ត្រីជាដើម ក្រោយព្រះវរនាំងនាក់តាមជលមាគ៌មក លុះថ្ងៃ ១៤កើតខែបុស្សឆ្នាំជូតចត្វាស័កនុ៎ះឯង ទើបស្តេចយាងដល់ទួលបាសាណ ស្តេចគង់នៅជាសុខសម្រាន្តក្នុងព្រះរាជវាំងបាសាណនោះបានត្រឹមតែជាង១ឆ្នាំប៉ុណ្ណោះ ដោយទឹកទន្លេបេះតែឡើងលិចទីនោះរាល់ឆ្នាំ ទើបព្រះអង្គមានព្រះរាជបញ្ជាឲ្យ សម្តេចចៅពញា (តែ) ខឹម ចុំគ្រាញ៉ាមហាភូបតី (ខៀវ) ព្រមដោយមន្ត្រីឯទៀតខ្លះផងដែលស្គាល់ទីដីមានជ័យភូមិ ឲ្យទៅពិនិត្យមើលទីដីនៅជិត ភ្នំដូនពេញ ឃើញថាទីដីនៅខាងទិសអគ្នេយ៍ភ្នំដូនពេញមានជ័យភូមិល្អ ព្រះអង្គក៏មានព្រះរាជបញ្ជាឲ្យកសាងព្រះរាជវាំងថ្មីត្រង់ទីនោះ ។

នៅថ្ងៃ៩កើតខែពិសាខឆ្នាំខាលឆស័ក ព.ស. ១៩៧៨ ច.ស. ៧៩៦ គ.ស. ១៤៣៤, ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ស្តេចយាងចេញចាកព្រះរាជវាំងបាសាណ, នៅថ្ងៃ ១៤ កើតខែពិសាខនុ៎ះឯង ស្តេចយាងចូលគង់ក្នុងព្រះរាជវាំងថ្មីនៅទិសអគ្នេយ៍ភ្នំដូនពេញ ។

នៅថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំម្សាញ់ នព្វស័ក ព.ស. ១៩៨១ ម.ស. ៧៥៩ គ.ស. ១៨៣៧ ព្រះអង្គប្រទាននាមក្រុងថ្មីនេះថា ក្រុងជ័យពុម្ពមង្គល, ឯទន្ទ ៤ មុខដែលគេធ្លាប់ហៅថា នគរប្រាបឈាម មកយូរហើយ ទ្រង់ប្រទានឈ្មោះថា នគរពុម្ពខ្ពង់តាំវិញ ។ល។ ព្រះអង្គមានព្រះពរបញ្ញាឲ្យ ឧកញ៉ា តោជោ (ស្រី) ទៅហ្វាយស្រុកសំពង-ទង ជាអ្នកកាន់ការលើកដីដាក់បំពេញទីក្រុងថ្មី តាំងឲ្យយកដីដាក់បំពេញគំនូរពេញឲ្យរាបស្មើល្អរៀងផង ។ ទីក្រហូងជ្រៅដែលកើតពីការជីកយកដីនោះជាប់មានឈ្មោះថា បឹងតោជោ រៀងមក គឺទីដីក្រុងផ្សារថ្មីសព្វថ្ងៃនេះ ។ល។ ទ្រង់មានព្រះពរបញ្ញាឲ្យ ឧកញ៉ា ផ្ទុង ទៅ-ហ្វាយស្រុកពាទី កាន់ការជីកព្រែក ១... ជាប់ហៅថា ព្រែកការឧក-ញ៉ាផ្ទុង លុះបំណេរកាលតមកហៅថា ព្រែកតាពាបផ្ទុង គឺក្រង-កន្ទួងស្ទួងដែលទុយនៅខាងកើតព្រះសក្យមុនីចេតិយសព្វថ្ងៃនេះ ។ល។

ព្រះបាទសម្តេចព្រះបរមបពិត្រ (ពញា យ៉ាត) ទ្រង់មានព្រះពរ-បញ្ញាឲ្យកសាងវិហារលើទីដីខ្ពស់ដែលដាក់ថែមថ្មី ទ្រង់កន្ទុងវិហារចាស់របស់ ដូនពេញ, ឲ្យកសាងចេតិយធំ ១ ពីខាងក្រោយវិហារ ។ល។ ទ្រង់បញ្ញត្តិឲ្យហៅភ្នំដូនពេញថា វត្តព្រះចេតិយបព៌ត ដូច្នេះវិញ (លុះបំណេរកាលតមក មហាជនតែងតែហៅក្លាយថា វត្តភ្នំដូន-ពេញ, អ្នកខ្លះហៅថា វត្តភ្នំពេញ ជាប់តរៀងមក) ។ ទ្រង់មាន

ព្រះរាជបញ្ជាឲ្យកសាងវត្ត ៦ ផងទៀតគឺ ១– វត្តកោះ នៅត្រង់ទិស ខាងកើតឆៀងអាគ្នេយ៍ភ្នំដូនពេញ ។ ២– វត្តលង្កា នៅត្រង់ទិស ខាងកើតឆៀងឦសានភ្នំដូនពេញ ។ ៣– វត្តព្រះពុទ្ធឃោសា នៅត្រង់ខាងត្បូងព្រែកចិនដំដែក ជាទិសខាងជើងភ្នំដូនពេញ ។ បានជាទ្រង់ព្រះរាជតាំងនាមវត្តទាំង ៣ នេះដូច្នេះ ដើម្បីឲ្យសមនឹងដំណើរ រឿងដែលថា ព្រះពុទ្ធឃោសាចារ្យទៅចម្លងគម្ពីរអំពីកោះលង្កា ។ ៤– វត្តពាមជុំ នៅខាងទិសអាគ្នេយ៍ភ្នំដូនពេញ ជិតជាប់ទីដីមាត់ ព្រែកឧកញ៉ាជុំ ឆ្ងាយបន្តិចពីវត្តកោះ ។ ព្រះពុទ្ធរូបអង្គធំដែលគង់ក្នុង វិហារវត្តពាមជុំនេះ មានព្រះនាមថា ព្រះស្រកាលេញ ព្រោះ គេទំបមាសមានសណ្ឋានរលេច ស្រដៀងនឹងស្រកាត្រីលេញ (១) ។ ៥– វត្តឧណ្ណាលោម ដែលមាននាមនេះស្រេចស្រាប់មកពីយូរហើយ ជានាមនៃចេតិយធំកណ្តាលចេតិយទាំង ៥ នៅខាងលិចវិហារវត្តឧណ្ណា-លោមសព្វថ្ងៃនេះ ។ ៦– វត្តឧត្តបតាយ៉ង់ ដោយយកនាមតាម្នាក់ឈ្មោះ

---

១ ព្រះស្រកាលេញអង្គនេះហើយដែលចៅពញាភក្តីសង្គ្រាម (ហុក) ជាមេទ័ពមានកេរ្តិ៍ឈ្មោះល្បីល្បាញ បានចូលទៅគោរពសំពះបួងសួងនៅពេលយប់ មុននឹងចុះហែលទឹកទន្លេទៅលបអញ្ជើញស្តេច សម្តេចព្រះទេវក្សត្រីជាព្រះជននីនាថ នៃព្រះបាទសម្តេចព្រះជ័យ-ចេស្តា ឲ្យបានរួចផុតពីកណ្តាប់ដៃនៃសត្រូវនៅស្រោយចង្វា, ក្នុងពុទ្ធសតវត្សរ៍ទី ២៣ ។ លុះបំណោរកាលមកខាងមុខ ព្រះពុទ្ធរូបស្រកាលេញអង្គនេះបានមកប្រតិស្ឋានក្នុងវត្តឧណ្ណាលោម គឺព្រះពុទ្ធរូបអង្គធំ ក្នុងវិហារវត្តឧណ្ណាលោមសព្វថ្ងៃនេះ ដែលបានត្រូវដួលផុលអស់វារៈ ៣ ដង ហើយ ឯព្រះនាមថា ព្រះស្រកាលេញនោះ ក៏រលុបបាត់ទៅឥតមានលេចឮឡើយ ។

យ៉ន់ ដែលជាអ្នកដឹកគ្ទប, លុះចំណោះកាលមកខាងមុខ, វត្តឧបកាយ៉ន គឺវត្តបទុមវតី សព្វថ្ងៃនេះ ។

ថ្ងៃ ១១ កើតខែពិសាខ ឆ្នាំចចត្វាស័ក ព.ស. ១៩៨៦ ច.ស. ៨០៤ គ.ស. ១៤៤២ ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ព្រមដោយខុំពជការគ្រប់តំណែង និងគណៈសង្ឃ មានសម្តេចព្រះសុគន្ធាធិបតីជាប្រមុខ បានធ្វើបុណ្យបញ្ចុះសីមាគ្រប់វត្តទាំង ៧ មានវត្តព្រះចេតិយបពិតជាដើម និងព្រះរាជពិធីជាការកុសលផ្សេង ៗ[1] ។ល។

## វត្តឧណ្ណាលោមក្នុងសម័យពមក

ឧណ្ណាលោម ជាពាក្យបាលី, ពាក្យសំស្ក្រឹតថា ឧណ៌ាលោម ប្រែថា «រោមប្រជុំចិញ្ចើម» គឺរោមដែលដុះត្រង់ប្រជុំនៃចិញ្ចើមទាំងពីរ ផ្សេងគ្នាពីរោមចិញ្ចើមប្រក្រតី ។ ក្នុងព្រះរាជពង្សាវតារប្រាប់ថា ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់ប្រទាននាមវត្តនេះតាមនាមដើមស្រាប់ ជានាមនៃចេតិយធំដែលបញ្ចុះព្រះឧណ្ណាលោមនៃ ព្រះអស្សជិតត្ថេរ ។ រឿងនេះ សម្តេចព្រះមហាសង្ឃរាជព្រះនាមទៀង (សុវណ្ណកេសរ:) មានព្រះបន្ទូលថា ចេតិយធំនឹងព្រះពុទ្ធរូប

---

១ គួរឲ្យនឹកស្តាយណាស់ ដោយព្រះរាជពង្សាវតារពុំប្រាប់ព្រះនាមនៃសម្តេចព្រះសុគន្ធាធិបតី និងនាមព្រមទាំងសមណស័ក្តិនៃព្រះរាជាគណៈឋានានុក្រមសង្ឃ និងលោកចៅអធិការនៃវត្តទាំង ៧ ក្នុងវេលាកាលនេះសោះ ។

អង្គធំ ដែលប្រតិស្ឋានក្នុងរូងខាងក្រោមនៃមហាចេតិយនោះ មានពាក្យបរម្បរតៗមកថា គេកសាងតាំងពីក្នុងសម័យដែលព្រះពុទ្ធសាសនាផ្សាយចូលមកក្នុងប្រទេសកម្ពុជានេះជាដំបូងបង្អស់ ។ ដីដែលគេកសាងចេតិយធំនេះកាលពីដើមជាដីខ្ពស់ជាងទីដីឯទៀតក្នុងតំបន់នេះ ដូចជាកោះតូចមួយៗ គ្រាន់ដែលជាបញ្ចុះព្រះឧណ្ណាលោមនៃព្រះអស្សជិតត្ថេរនោះ សម្ដេចព្រះមហាសង្ឃរាជមានព្រះបន្ទូលថា ជាពាក្យបរម្បរតៗមកដែរ ពុំដឹងជាព្រះអស្សជិតត្ថេរនោះក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយ៍អង្គណា ក្នុងសម័យណាទេ តាំងចេតិយធំនឹងព្រះពុទ្ធរូបអង្គធំនោះ ក៏ពុំដឹងជាព្រះមហាក្សត្រិយ៍អង្គណា ឬលោកណាឈ្មោះអ្វីកសាងឡើយ ។

គួរអស់លោកអ្នកអានប្រវត្តិនេះ សង្កេតពិនិត្យមើលសណ្ឋានទ្រង់-ទ្រាយចេតិយធំកណ្ដាលដែលហៅថា 'ចេតិយឧណ្ណាលោម' គឺគង់កាច់ជ្រុង" ព្រមទាំងស្ថានបាទុផងទៀតថា ក្នុងប្រទេសកម្ពុជាទាំងមូល ឬទោះទាំងក្នុងប្រទេសពុទ្ធសាសនិកឯទៀតក៏ដោយ មានតែចេតិយឧណ្ណាលោម ១ នេះឯង ដែលមានរូបប្លែកគេមានតែ ។ ចំណែកខាងព្រះពុទ្ធរូបអង្គធំ ដែលប្រតិស្ឋានចំកណ្ដាលរូងខាងក្រោមនៃចេតិយធំនេះ ក៏មានទ្រង់ទ្រាយដូចគ្នានឹងព្រះពុទ្ធរូបទាំងឡាយក្នុងសម័យបុរាណព្រេង-នាយនោះដែរ ។

x

x x



រូបមហាចេតិយឧណ្ណាលោម

ប្រវត្តិនៃវត្តឧណ្ណាលោម មានរឿងកំបាំងខាងដើមដូចពណ៌នាមក នេះឯង ។ លុះចំណេរកាលតៗមក ទើបប្រវត្តិនៃវត្តនេះមានរូបការគួរថ្លែង បានតាមលំដាប់កាល ដូចមានសេចក្ដីរៀបរាប់តទៅនេះ:

លុះដល់មកពុទ្ធសតវត្សរ៍ទី ២៣ គឺកាលពីឆ្នាំបនស័ក ព.ស. ២២៣៨ ច.ស. ១០៥៦ គ.ស. ១៦៩៤ ក្នុងរជ្ជកាលនៃ ព្រះបាទសម្តេចព្រះជ័យជេស្ឋា, ក្នុងព្រះរាជពង្សាវតារខ្មែរ មានថ្លែងប្រាប់ថា ព្រះពោធិវង្ស (ឯក) ចៅអធិការវត្តឧណ្ណាលោម និងព្រះស្រី-សត្ថាមុនី (អ៊ី) ចៅអធិការវត្តព្រះចេតិយបព៌ត បានថ្វាយព្រះពរព្រះរាជាថា ទីដីទួលព្រះស្រីនេះចង្អៀតណាស់ ពុំសមល្មមនឹងកសាងព្រះរាជ-វាំងតាមព្រះរាជហឫទ័យផងនោះទេ បើសព្វព្រះរាជហឫទ័យនឹងកសាងព្រះរាជវាំងថ្មីទុកជាទីរលឹកដល់ការមានជ័យឈ្នះបច្ចាមិត្រនោះ គួរកសាងនៅទីជិតបឹងក្បូវវិញ ព្រោះមានទីដីទូលំទូលាយស្រួល ៗ ព្រះបាទសម្តេចព្រះជ័យជេស្ឋាក៏សព្វព្រះរាជហឫទ័យយល់ស្របតាម ហើយព្រះអង្គមានព្រះរាជបញ្ជាឲ្យកសាងព្រះរាជវាំងមួយនៅជិតបឹងក្សួន ហៅថា ព្រះរាជ-វាំងបឹងក្រៀង នៅខាងទិសពាយ័ព្យនៃក្រុងភ្នំពេញសព្វថ្ងៃនេះ ប៉ុន្តែឥឡូវនេះព្រះរាជវាំងនោះរលំរលាយបាក់បែកបាត់អស់ទៅហើយ ។ ក្នុងរជ្ជកាលនេះ ព្រះពោធិវង្ស (ឯក) នោះ ជាទីប្រឹក្សាក្នុងការផ្ទៀងផ្ទាត់ច្បាប់សម្រាប់តុលាការ ដែលចាស់ៗហៅថា ក្រមច្បាប់ព្រះជ័យជេស្ឋានោះផង តាំងច្បាប់វិន័យខាងព្រះពុទ្ធសាសនាក៏បានពិនិត្យផ្ទៀងផ្ទាត់កម្រឹតកម្រង់ផងដែរ ។

សរសេចក្តីឲ្យឃើញថា តាំងពីក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះ

បរមពជា (ពញាយ៉ាត) រៀងរហូតមកដល់សម័យបច្ចុប្បន្ន វត្តឧណ្ណាលោម រមែងតែមានកិត្តិសព្ទនៅជាប់មិនដែលដាច់ដាពបមក គ្រាន់តែពុំច្បាស់ថា តំណចៅអធិការពីមួយមកមួយទៀតតៗគ្នារៀងមក តើមានប៉ុន្មានតំណហើយ? មានឈ្មោះអ្វីខ្លះ? សុទ្ធតែមានសមណសក្តិជាអ្វីខ្លះ? ឬប្រែខ្លះឥតមានសមណសក្តិជាអ្វីទេ? ប៉ុណ្ណោះឯង ។ ក្នុងព្រះពងពង្សាវតារមានសេចក្តីបញ្ជាក់បានតែត្រឹម ព្រះពោធិវង្ស (ឯក) មួយប្រប៉ុណ្ណោះ ក្នុងរជ្ជកាលនៃ ព្រះបាទសម្តេចព្រះជ័យជេដ្ឋា (ព.ស. ២២៣៨ ច.ស. ១០៥៦ គ.ស. ១៦៩៤, គិតមកដល់ ព.ស. ២៥០៥ នេះឃើញ ២៦៧ ឬ ២៦៨ ឆ្នាំហើយ) ។ លុះដល់មករជ្ជកាលនៃ ព្រះបាទសម្តេចព្រះនរោត្តម (បរមរាមទេវាវតារ . . .) ដែលព្រះអង្គស្តេចយាងចេញចាកក្រុងឧដុង្គមានជ័យ មកគង់ក្នុងក្រុងភ្នំពេញ, ទើបប្រវត្តិនៃវត្តឧណ្ណាលោមជាក់ច្បាស់តាមលំដាប់កាលរៀងរហូតមក ដូចមានសេចក្តីរៀបរៀងតទៅនេះ:

## វត្តឧណ្ណាលោម ក្នុងបឋមសម័យ

នៅថ្ងៃព្រហស្បតិ៍ ៤ កើតខែបុស្ស ឆ្នាំឆ្លូវសប្តស័ក ព.ស. ២៤០៩ ម.ស. ១៧៨៧ ច.ស. ១២២៧ គ.ស. ១៨៦៥ វេលាម៉ោង ៩ ព្រឹក ព្រះបាទសម្តេចព្រះនរោត្តម (បរមរាមទេវាវតារ . . .) ស្តេចយាងចេញចាកព្រះបរមរាជវាំង ស្រះសារតើយុត្ត ក្រុងឧដុង្គមានជ័យ មក

គង់ឯក្រុងភ្នំពេញចតុមុខនគរ (ជាគ្រាទី២ តពីគ្រាទី១ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះបរមរាជាពញាយ៉ាត) ។ល។ សម្តេចព្រះមហាសង្ឃរាជ ព្រះនាមទៀង និងព្រះរាជាគណៈជាអនុក្រមច្រើនរូប មានព្រះមហាវិមលធម្មនាម ពុយ និងព្រះពុទ្ធឃោសាចារ្យនាម ទ្រាក់ ជាដើម ក៏បាននាំចេញចាកវត្តប្រាគ្គ ក្រុងចតុមុខមានជ័យមកគង់នៅវត្តឧណ្ណាលោមនេះ ។

វត្តឧណ្ណាលោម មានចៅអធិការស្រាប់មក មាននាមថា លោកតាក្រុ កង់, តមក មានសមណសក្តិទីពជាគណៈជាព្រះធម្មវង្ស, គេប្រើនហៅលោកថា លោកតាតា កង់ ព្រះធម្មវង្ស, លោកមានកុដិប្រក់ស្បូវ ១ ខ្នងជាលំនៅរបស់លោក នៅត្រង់ទិសខាងជើងមហាចេតិយឧណ្ណាលោម ។ លុះសម្តេចព្រះមហាសង្ឃរាជមកគង់នៅវត្តនេះ លោកតាកង់ក៏សូមថ្វាយឋានៈចៅអធិការវត្តឧណ្ណាលោមមកសម្តេច ប៉ុន្តែសម្តេចពុំព្រមទទួល ។ លុះបំណាច់កាលតមក លោកព្រះធម្មវង្សកង់ ទទួលអនិច្ចធម្មទៅ, ឋានៈចៅអធិការវត្តឧណ្ណាលោមក៏រំកិលមកលើសម្តេចព្រះមហាសង្ឃរាជ ព្រោះសម្តេចជាប្រមុខនៃសង្ឃស្រាប់ ។

៙

៙ ៙

# តំណចៅអធិការវត្តឧណ្ណាលោម

## ក្នុងបច្ឆិមសម័យ

ចាប់ដើមតាំងពី ព្រះបាទសម្តេចព្រះនរោត្តមស្តេចមកគង់នៅក្រុងភ្នំពេញ រៀងរហូតមកដល់សម័យបច្ចុប្បន្ននេះ វត្តឧណ្ណាលោមមានចៅអធិការ ៥ តំណគឺ:

១– ព្រះធម្មវិជ្ជា គង់;

២– សម្តេចព្រះមហាសង្ឃរាជ ព្រះនាម ទៀង (សុវណ្ណកេសរៈ);

៣– សម្តេចព្រះធម្មលិខិត ព្រះនាម អ៊ុក ជាព្រះសង្ឃនាយកគណៈមហានិកាយ;

៤– ព្រះមហាវិមលធម្ម ថោង-គង់ ជាមន្ត្រីសង្ឃទីរៀនហ្វូនៈ

៥– ព្រះពុទ្ធឃោសាចារ្យ ជួន-ណាត (ជោតញ្ញាណោ), តមក មានសមណសក្តិជា ព្រះពោធិវង្ស ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ផង ជាអធិបតីនៃថេរសភាគណៈមហានិកាយផង, តមកទៀត មានសមណសក្តិជា ព្រះមហាសុមេធាធិបតី សង្ឃនាយក, តពីនោះមកជា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ (នៃប្រទេសកម្ពុជា); រដ្ឋាភិបាលសហភាពភូមាបានសុំតាំងជា អគ្គមហាបណ្ឌិត, តមក បាន

សុំតាំងឲ្យឡើងជា អគ្គធម្មៈមហារដ្ឋគ្រូ ជាសមណស័ក្តិខ្ពស់បំផុត សម្រាប់ប្រទេសកម្ពុជា ។

## បរិមាណនៃទីដីវត្តឧណ្ណាលោម

វត្តឧណ្ណាលោម មានផ្ទៃដីរាងជាបន្ទាត់ពុំស្មើគ្នាទេ ដូចខាងក្រោមនេះ៖

១– ខ្សែកាខាងត្បូង ពីទីបំផុតកំពែងខាងកើត ដល់ទីបំផុតខាងលិច ១៤៩ ម៉ែត្រ;

២– ខ្សែកាខាងលិច ពីទីបំផុតកំពែងខាងត្បូងដល់ទីបំផុតខាងជើង ១៦៩ ម៉ែត្រ (វែងលើសខ្សែទី ១-៣-៤ ចំនួន ២០ ម៉ែត្រ);

៣– ខ្សែកាខាងជើង ពីទីបំផុតកំពែងខាងលិចដល់ទីបំផុតខាងកើត ១៤៩ ម៉ែត្រ;

៤– ខ្សែកាខាងកើត ពីទីបំផុតកំពែងខាងជើងដល់ទីបំផុតខាងត្បូង ១៤៩ ម៉ែត្រ ។

កាលពីដើម ទីដីខាងមុខវត្តនេះ តាំងពីព្រំវត្តហូតដល់មាត់ទន្លេ (ស្ពានទីព្រំវត្ត) ជាដីធរណីសង្ឃ គឺជាដីសម្រាប់វត្តឧណ្ណាលោមទាំងអស់ ហៅថា លាភសីមា ឬ ដីចំណាវត្ត ប៉ុន្តែឥតដែលបានផលប្រយោជន៍អ្វីបន្តិចបន្តួចដល់វត្តឧណ្ណាលោមទេ ។ លុះចំណេរកាលតមក ទីដីខាងមុខវត្តនេះក៏ក្លាយជាដីរបស់ក្រុងភ្នំពេញអស់ទៅ ។ លុះដល់មក

សម័យប្រទេសកម្ពុជាឯករាជ្យអព្យាក្រឹត រាជការក្រុងភ្នំពេញបានបង្វែរទីដីមាត់ទន្លេខាងមុខវត្ត ប្រវែង ២០ ម៉ែត្រ ឲ្យជាដីកំពង់សម្រាប់វត្តឧណ្ណា-លោម ។ល។

## ការរៀបចំវត្តឧណ្ណាលោម

ដើម្បីកុំឲ្យប្រវត្តិនៃវត្តឧណ្ណាលោមមានសេចក្ដីពិស្ដារវែងពេក, លំ-ដាប់តទៅនេះ សូមពណ៌នាដោយសង្ខេប ព្រោះក្នុងសម័យបច្ចុប្បន្ននេះ អស់លោកអ្នកអានប្រវត្តិនេះសុទ្ធតែបានឃើញបានជ្រាបអស់ហើយ ។

កាលដែលសម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង មកគង់ក្នុងវត្តឧណ្ណាលោម វត្តនេះមានទីដីក្រហែងក្រហូងខ្ពស់ខ្លះទាបខ្លះ ពុំទាន់បានស្អាតស្អំសមរម្យនៅឡើយទេ, លុះចំណេរកាលតៗមក វត្តឧណ្ណាលោមក៏មានសភាពចំរើនតាមលំដាប់កាល ដូចរៀបរាប់ដោយសង្ខេបតទៅនេះ:

១– ក្រោយពីពេលដែលព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះនរោត្តម ស្ដេចទៅគង់ឯព្រះបរមរាជវាំងចតុមុខ គឺព្រះបរមរាជ-វាំងសព្វថ្ងៃនេះ, ព្រះបាទសម្ដេចព្រះនរោត្តម ទ្រង់មានព្រះរាជបញ្ជាឲ្យពួកមេការរុះរើព្រះដំណាក់នៅព្រះរាជវាំងកំពត (ព្រះរាជវាំងសំបក) នៅខាងជើងវត្តឧណ្ណាលោម ឲ្យយកមកសង់ជាដំណាក់ឥដ្ឋមានជាន់ ២ ថ្វាយសម្ដេចព្រះមហាសង្ឃរាជ គឺកុដិមួយខ្នងនៅខាងទិសអាគ្នេយ៍វិហារ (កុដិដែលព្រះពុទ្ធឃោសាចារ្យ ជេង-ម៉ុល នៅគង់គ្រប់គ្រងរក្សាសព្វថ្ងៃនេះ)។

លុះតមក ព្រះពុទ្ធឃោសាចារ្យ ផែន.ប៊ុល បានដួសដុលឡើងជាថ្មី ធ្វើឲ្យមានផ្លូវចូលពីខាងជើងវិញ ។

២– សម្តេចព្រះមហាសង្ឃរាជ និងពុទ្ធបរិស័ទ បានកសាងវិហារទិសចេតិយ ៤ ជុំវិញភ្ជាប់គ្នានឹងមហាចេតិយឧណ្ណាលោម, ព្រមទាំងបានឲ្យជាងធ្វើឆត្រត្រដាក់លើកំពូលនៃមហាចេតិយផង ។ល។

៣– បានតំកល់ព្រះបរមសារីរិកធាតុ នៃព្រះសក្យមុនីសម្មាសម្ពុទ្ធបរមគ្រូដែលសមណទូតឈ្មោះវេង ឆ សភារៈ ជាតំណាងនៃសម្តេចព្រះសង្ឃ-រាជព្រះនាម សិរីសុមង្គលៈ នៅវត្តវិទ្យាលយបរិវេណ ក្រុងកោលុម្បស្រីលង្កាទ្វីប នាំយកមកថ្វាយព្រះបាទសម្តេចព្រះនរោត្តម, សឹងមានអក្សរចារឹកនៅលើបាតទ្វារខាងកើត នៃមហាចេតិយឧណ្ណាលោមជាភស្តុតាងស្រាប់ ។ ក្នុងវិហារចេតិយទាំង ៤ ជុំវិញមហាចេតិយ ដែលតំកល់ព្រះបរមសារីរិកធាតុនោះ សុទ្ធតែមានព្រះពុទ្ធរូបមួយអង្គ ៗ រួមទាំងព្រះពុទ្ធរូបចំ-ពីបុរាណដែលឋិតនៅក្នុងវិហារកណ្តាលផងជា ៦ ព្រះអង្គ ។ល។

៤– ឯចេតិយទាំងឡាយ នៅទីលំពបរវាងក្រោមជុំវិញមហាចេតិយនោះ សុទ្ធតែពុទ្ធបរិស័ទបានកសាងតំកល់ឆ្អឹងអដ្ឋិធាតុនៃអ្នកមានគុណរបស់ខ្លួន ដោយបានអនុញ្ញាតអំពីសម្តេចព្រះមហាសង្ឃរាជ ។ល។

៥– លុះបំណោរកាលតមក លោកអ្នកឧកញ៉ា អក្ខយភោ-សេដ្ឋា (ប៉ុគរ) ជាប្រមុខនៃពុទ្ធបរិស័ទ បានសូមអនុញ្ញាតសម្តេច

ព្រះមហាសង្ឃរាជ ហើយបានជួសជុលវិហារថ្មី ជញ្ជាំងឥដ្ឋចាស់ស្រាប់ គ្រឿងលើ ប្រក់ក្បឿងព័ណ៌ ប៉ុន្តែទំហំវិហារទុកឲ្យនៅដូចដើម ។ល។

៦– ក្នុងកាលនៃ ព្រះមហាវិមលធម្ម (កែវ-គង់) ជាចៅអធិការ, សេនាសនៈផ្សេងៗ មានទបង្អូនសាលា និងសាលាបាលីរងជាដើម បានកើតមានឡើងក្នុងវត្តចុណ្ណាលោម, វត្តនេះមានការលូតលាស់ចំរើន រៀងៗរៀងរាល់ឆ្នាំតាមរយៈពេលកាល ។ សាលាធំ ១ ខ្នង នៅទិសខាងកើតធៀបព្រះវិហារ ដែលលោកអគ្គកញ្ញាឧត្តមមហាសេនា (ប៉ុក) កាលនៅជា ក្រឡាហោម បានកសាង និងសាលាធំ ១ ខ្នងទៀតនៅជាប់ទីដំណាក់សម្តេចព្រះមហាសង្ឃរាជ ដែល លោកអ្នកឧកញ៉ា ក្រឡាហោម (សៅ) បានកសាង ក៏បានត្រូវរុះរើយកគ្រឿងសម្ភារៈមកផ្សំធ្វើជាសាលាបាលីរងនឹងសេនាសនៈដទៃខ្លះទៀតឲ្យជាស្ថាពរតរៀងទៅ ។ល។

៧– ពុទ្ធបរិស័ទបានកសាងកុដិធំ ១ ខ្នង ហៅថា មហាកុដិ នៅខាងជើងវិហារ ។ អ្នកឧកញ៉ាអភិធរភជវេជ: (តាំង-យ៉េ) មានសទ្ធាជ្រះថ្លាចំពោះការកសាង ឈាបនដ្ឋាន (ទីសម្រាប់បូជាសព) សម្រាប់វត្តចុណ្ណាលោម, ដោយចៅអធិការបច្ចុប្បន្នគឺ ស.ស.ជ.ណ. ជោត ញាណោ បានយល់ស្របផង, បានសូមព្រះបរមរាជានុញ្ញាតព្រះករុណាជាម្ចាស់ជីវិត ហើយបានកសាងឈាបនដ្ឋានដំបូង

ដែលប្រទេសកម្ពុជា ពុំធ្លាប់ដែលមានឈាបនដ្ឋានបែបនេះសោះនៅឡើយ ដោយពុទ្ធបរិស័ទមានភាគច្រើនបានជួយកសាងថែវជាបរិវេណ និងគ្រឿងបរិក្ខារផ្សេងៗផង ។ល។

៨– ដោយចៅអធិការបច្ចុប្បន្នគឺ ស.សរ.ជ.ណា. ជោត-ញាណោ និងពុទ្ធបរិស័ទភាគច្រើន មានលោក ផា-ឌុជ ជាដើម យល់ឃើញថា វិហារវត្តខណ្ណាលោមនេះ មានដំបូលនិងពិតានកាន់តែទ្រុឌទ្រោមណាស់ទៅហើយ និងដំអក់បណ្ដោយទុកឲ្យនៅយូរទៅទៀតពុំកើត, ក៏ព្រមព្រៀងគ្នា បានសូមព្រះបរមពជានុញ្ញាតព្រះករុណាជាម្ចាស់ជីវិត ហើយរុះរើវិហារចាស់ បានកសាងវិហារថ្មីសព្វថ្ងៃនេះឡើង ។ល។

## ចំនួនភិក្ខុសាមណេរនឹងយុវជន

តាំងពីក្នុងសម័យ នៃសម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង រៀនផកបមក, ដល់ឆ្នាំ, វត្តខណ្ណាលោម មានភិក្ខុសាមណេរចំនួនជាង ៤ រយម្ភួទកាលជាង ៥ រយរូប សុទ្ធសឹងតែមកពីខេត្តក្រៅ ស្ទើរតែទាំងអស់, ច្រើនតែមកនៅរៀនព្រះបរិយត្តិធម៌, ពោះបីមានការលំបាកដោយអាហារបិណ្ឌបាតយ៉ាងណា ក៏ចេះតែទ្រាំនៅ ។ ចំណែកខាងកុមារនិងយុវជន (គ្រហស្ថ) ក៏មានចំនួនច្រើនណាស់ ស្ទើរតែស្មើគ្នានឹងភិក្ខុសាមណេរដែរ ជួនកាលឆ្នាំខ្លះ ច្រើនលើសជាងភិក្ខុសាមណេរទៅទៀតក៏មាន ។

តាមការណ៍ពិត, កូនចៅអ្នកក្រីក្រទាំងឡាយនៅខេត្រក្រៅ ដែលឥតចិញ្ចឹមពំនាក់នៅក្នុងក្រុង គ្មានប្រាក់ជួលផ្ទះនៅ គ្មានអាហារូបករណ៍, ព្រះរាជរដ្ឋាភិបាលក៏ពុំអាចនឹងជួយទំនុកបំរុងបានឡើយ ព្រោះមានចំនួនច្រើនគ្នាណាស់រាប់រយពាន់, ចុំានប្រាក់បរិកាពីណា ទឹងលៃលកជួយផ្គត់ផ្គង់កើត ? ដោយហេតុនេះ បើកុំតែបានវត្តអារាមក្នុងក្រុង ជាទីជ្រករៀនសូត្រនោះ កុមារនឹងយុវជនអស់នោះ ពុំអាចនឹងញ៉ាំងខ្លួនឲ្យជាអ្នកមានចំណេះវិជ្ជាគួរដល់ការបានឡើយ, កូនចៅអ្នកក្រីក្រក៏មុខជានឹងសុទ្ធតែជាពលរដ្ឋល្ងង់ខ្លៅតពូជតវង្សពុំខាន ៗ តាមការណ៍ពិតមួយយ៉ាងទៀត, វត្តឧណ្ណាលោមនេះក្តី វត្តទាំងឡាយឯទៀតក្នុងក្រុងភ្នំពេញនឹងក្នុងក្រុងធំតូចនៅខេត្រក្រៅក្តី សុទ្ធតែជាទីឋានសម្រាប់ជួយសម្រាលសេចក្តីតានតឹងនឹងភារៈដ៏ធ្ងន់ធ្ងររបស់ប្រទេសជាតិមាតុភូមិ ឬនឹងរាប់ថាវត្តអារាមទាំងនេះជា គិលានដ្ឋាន សម្រាប់ជួយរម្ងាប់ជម្ងឺល្ងង់ខ្លៅ ស្រវាក់ស្រវាន់ភ័ន្តច្រឡំដែលជា បដិច្ឆន្នាពាធ «ជម្ងឺកំបាំង» នៃកុមារនឹងយុវជនទាំងឡាយជាកូនចៅអ្នកកំសត់ទុគ៌តផងទៀតក៏សឹងតែបាន ៗ អាស្រ័យហេតុខាងលើនេះ បានជាអស់លោកគ្រប់កុដិរាល់វត្តក្នុងក្រុង, ទោះបីចង្អៀតចង្អល់ទញ់ទ័លពុំគ្រាន់យ៉ាងណាក៏បេះតែធន់ទ្រាំទទួលបន្ទុកជួយសង្គ្រោះកុមារនឹងយុវជនកំសត់ទុគ៌ត ជាប់ជាប្រពៃណី ដោះដៃគ្មានបដិសេធចោលពុំកើត ៗ មានជនខ្លះយល់ថា ការនៅជ្រកអាស្រ័យក្នុងវត្ត គេច្រើនតែ

មើលងាយថា កុមារនេះយុវជនអ្នក នៅជ្រកកង់វត្តសុទ្ធតែជាមនុស្សសាបលោប ។ល។ ការយល់យ៉ាងនេះ ពិតទេះមិនពិតទេះ; គួរអស់លោកអ្នកមានវិចារណញ្ញាណ រិះរកមើលដោយល្អិតល្អន់ហ្មត់ចត់ផងចុះ ។

## បុរាណនៃវត្តឧណ្ណាលោម

វត្តឧណ្ណាលោម បើនិយាយពីប្រវត្តិនៃមហាចេតិយកណ្តាលខាង-លិចវិហារសព្វថ្ងៃនេះ នឹងព្រះធាតុរូបចម្លងអគ្គីជំនួសរូបនៃមហាចេតិយនោះ ពុំដឹងជាកើតមានពីក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយ៍អង្គណា ពីក្នុងពុទ្ធ-សតវត្សរ៍ទីប៉ុន្មានទេ, ប៉ុន្តែ បើនិយាយពីត្រឹមរជ្ជកាលនៃព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ដែលព្រះអង្គមានព្រះរាជបញ្ជាឲ្យកសាងវត្តនេះឡើងវិញទៀត ហើយទ្រង់ធ្វើបុណ្យបញ្ចុះសីមានៅថ្ងៃ ១១ កើតខែពិសាខ ឆ្នាំចចត្វាស័ក ព.ស. ១៩៨៦, គិតពីឆ្នាំនោះមកដល់ឆ្នាំខាលចត្វាស័ក ព.ស. ២៥០៥ នេះ ឃើញថាមានបុរាណ ៥១៩ ឆ្នាំ ឬ ៥២០ ឆ្នាំហើយ ។

# អនុស្សរណោវាទ (ផ្សេងពីប្រវត្តិ)

## ចំពោះយុវជនអ្នកនៅវត្ត

ហៃពួកយុវជនអ្នកកំសត់ បើកុំបានវត្តជ្រកអាស្រ័យ
សមអ្នកនឹងឥតមានតម្លៃ យប់ថ្ងៃហួសទៅឥតប្រយោជន៍ ៗ
គួរអ្នកកុំភ្លេចវត្តលំនៅ ពោះអ្នកចេញទៅឆ្ងាយស្រែឡាប
គួរដឹងគុណវត្តកុំបំភ្លេច ប្រយោជន៍នឹងផលផ្តល់ពុំខាន ៗ
បើមានគេសួរពីកាលរៀន បំណះរបៀនតាំងបុរាណ
អ្នកកុំនិយាយបន្ទំផាន ត្រូវប្រាប់ថាបានចេះព្រោះវត្ត ៗ
កុំពោលបង្អួតពួកស្រីៗ ត្រូវស្តីតាមត្រង់កុំបំភ្លាត់
បំផ្លើសបំភ្លើ បំភ្លេចវត្ត ក្រែងទោសទាញទាត់ឲ្យវិនាស ៗ
បាយវត្តជាភោជន៍មានព្រលឹង គួរនឹករំពឹងកុំទិសទាស
នាមុនបន្ទឹមកពីស្រែ ពីស្រែឡើងទៅជាបន្ទី ៗ
បាយផ្ទះបាយវត្តដូចជាគ្នា បំបែកកេគ្នាមានដី
ខ្ពង់ហើយរៀនសូត្រចេះខ្ចប់ខ្ចី មុខកើតមានដោយសារវត្ត ៗ

សាធុ! សូមឲ្យអ្នកបានសុខ និទុក្ខនិភ័យសិរីសួ
ជាជនសប្បុរសរបស់រដ្ឋ មានរបៀបមានបទប្រសើរហោង!



# វិហារថ្មីវត្តឧណ្ណាលោម

វិហារថ្មីវត្តឧណ្ណាលោម ចាប់ផ្ដើមស្ថាបនាក្នុងឆ្នាំរកានពស័ក ព.ស. ២៥០០ គ.ស. ១៩៥៧, បានស្ថាបនាហើយស្រេចក្នុងឆ្នាំជូតទោស័ក ព.ស.២៥០៣ គ.ស. ១៩៦០ ។ ដល់មកឆ្នាំថោះបញ្ចស័ក ព.ស. ២៥០៦ គ.ស. ១៩៦៣ ទើបបានធ្វើបុណ្យឆ្លងអស់វេលា ៣ យប់ ៤ ថ្ងៃ គឺនៅថ្ងៃទី ១-២-៣-៤ មិថុនា ១៩៦៣ ។

កាលដែលពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ មានខ្ញុំ (សម្ដេចព្រះមហាសុមេធាធិបតី ជ. ណ. ជោតញ្ញាណោ) ជាប្រមុខ បានប្រជុំប្រឹក្សាគ្នានឹងស្ថាបនាវិហារថ្មីនេះ ក្រុមសន្និបាតមានយោបល់ស្របគ្នាថា វត្តឧណ្ណាលោមនេះមានទីដីបង្អៀតណាស់ នឹងលៃលកស្ថាបនា សាលសម្រាប់មហាសន្និបាតខាងព្រះពុទ្ធសាសនាម្ដងៗ ដែលជាការចាំបាច់នោះពុំកើត, ដោយហេតុនេះ ត្រូវតែសាងសង់វិហារក្នុងវត្តនេះឲ្យធំទូលាយជាងវិហារចាស់, ត្រូវធ្វើឲ្យមាន ៣ ជាន់ ដើម្បីឲ្យងាយប្រើប្រាស់តទៅ, កាលបើបានស្ថាបនារួចស្រេចហើយ ត្រូវយកជាន់ក្រោមជាសាលមហា-សន្និបាត, ជាន់កណ្ដាលសម្រាប់ប្រើការដូចវិហារវត្តទាំងពួងទៀត, ជាន់លើបំផុតសម្រាប់តំកល់ព្រះពុទ្ធរូបអង្គធំនឹងព្រះពុទ្ធរូបអង្គតូចៗទាំងពួង ។ល។

វិហារនេះ មានបណ្ដោយ ៦៩ម.៦០ ដោយមិនគិតដល់កទហាលជណ្ដើរផងទេ, មានទទឹង ២១ម.៤០, កំពស់ពីផែនដីដល់កំពូល ៣៩ ម៉ែត្រ ដោយវិហារនេះមានខ្នាតទទឹងបណ្ដោយពុំស្របគ្នាដូចវិហារដទៃទៀត ទើបធ្វើឲ្យមានមុខ ៤ មានកំពូលផង ។ល។

ក្លោងទ្វារខាងមុខវិហារ ទទឹង ៥ម.៣៩, បណ្ដោយ ៣ម.៦៦, កំពស់ពីផែនដីដល់កំពូល ១៣ ម៉ែត្រ ។

ការស្ថាបនាវិហារ រួមទាំងការជួសជុលព្រះពុទ្ធរូបអង្គធំ និងការរើប-ម៉ាសព្រះពុទ្ធរូបគ្រប់ព្រះអង្គផង មានតម្លៃ ៥.០៣៥.៥៥៦ រៀល, ដោយមិនគិតតម្លៃគ្រឿងតំណាំប្រាក់សម្បូរ និងឥដ្ឋតំណាំដែលក្រាលត្រង់ព្រះគ្រឹះថ្នាក់កណ្ដាលផងទេ ព្រោះសម្ភារៈទាំង ២ មុខនេះជារបស់វិហារចាស់ ។ តម្លៃក្លោងទ្វារចំនួន ១៦៥.៤៧៤ រៀល ។ តម្លៃការជួសជុលមហាចេតិយទណ្ណាលោម និងចេតិយបន្ទាប់ទាំង ៥ ព្រមទាំងការលាបថ្នាំចេតិយពំគូបទាំងអស់ និងការក្រាលឥដ្ឋនិងស៊ីម៉ងត៍ លើទីលាននៃចេតិយទាំងនោះផងអស់ចំនួន ១០៣.៣៦៣ រៀល ។, បូករួមតម្លៃនៃការស្ថាបនាទាំងអស់ខាងលើនេះ មានចំនួនប្រាំលានបីសែនប្រាំពីរពាន់ប្រាំពីររយ ដប់ប្រាំបួនរៀល (៥.៣០៧.៧១៩,០០ ។

បើគិតទាំងកៅអីឈើខ្ទឹម មានដៃជាប្រទាប់សម្រាប់សរសេរ និងកៅអីឈើខ្ទឹមគ្មានដៃប្រទាប់, រួមកៅអីទាំង ២ ប្រភេទនេះ, មានចំនួន ៨៥០

ដែលពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ បានកសាងដាក់ក្នុងវិហារថ្នាក់ខាងក្រោម មានតម្លៃប្រមាណសរុបចំនួន ១៤១.៥០០ រៀល យកមកបូកផ្សំជា-មួយផង (ព្រោះជារបស់កើតមានឡើងជាមួយគ្នានឹងការស្ថាបនាវិហារដែរ) នោះឃើញប្រាំលាន បួនសែនពីរម៉ឺន ប្រាំបួនពាន់ពីររយ ដប់ប្រាំបួនរៀល (៥.៤២៩.២១៩៛០០) ។

ការស្ថាបនាសេនាសនៈនេះ ជាសមិទ្ធិផលផ្នែកព្រះពុទ្ធសាសនា កើតមានឡើងក្នុងសម័យនៃសង្គមរាស្ត្រនិយម ដោយមាន សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋកម្ពុជា ជាព្រះអគ្គមគ្គុទ្ទេសក៍ ព្រះពុទ្ធសាសនូបត្ថម្ភក៍ ។ ក្នុងការស្ថាប-នាវិហារនេះ សម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិ នឹងសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គបានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គចំនួនមួយសែនប្រាំពីរម៉ឺនរៀល (១៧០.០០០៛០០) ជាព្រះរាជកុសលដ៏ឧត្តម ជួយឧបត្ថម្ភជាមួយនឹងពុទ្ធបរិស័ទជា បុត្រ-ធីតា-ឧត្តា របស់ព្រះអង្គ ។

ថ្ងៃ៥ ៩ ៦ ឆ្នាំថោះបញ្ចស័ក ត្រូវនឹងថ្ងៃទី ១៦ ឧសភា ព.ស. ២៥០៦ គ.ស. ១៩៦៣ ។

សម្តេចព្រះមហាសុមេធាធិបតី
ជួន-ណាត
ជោតញ្ញាណោ

## មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារត្រៃរតន៍"

# 136$E_0$ វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ 012 706 581

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។